ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ : ២៩១៤ អយក.ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនិងលក្ខណាវិនិច្ឆ័យលម្អិត
## សម្រាប់ដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិត

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/៣៤៩ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណាវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ

- បានឃើញអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- បានឃើញអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- បានឃើញអនុក្រឹត្យលេខ១៥១ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការបណ្តុះបណ្តាលថ្នាក់បណ្ឌិត
- បានឃើញអនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំគោលការណ៍ណែនាំនិងនីតិវិធីក្នុងការដឹកនាំ ការការពារសារណា និងនិក្ខេបបទ
- បានឃើញប្រកាសលេខ១៤៣៥ អយក.ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីលក្ខខណ្ឌ និងលក្ខណវិនិច្ឆ័យលម្អិតសម្រាប់បង្កើតគ្រឹះស្ថានឧត្តមសិក្សា
- បានឃើញសេចក្តីសម្រេចលេខ០៤/០៨ គទក.សសរ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការអនុវត្តកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីតនិងការផ្ទេរក្រេឌីតរបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- បានទទួលការឯកភាពពីកិច្ចប្រជុំថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា នាថ្ងៃទី៣ ខែមេសា ឆ្នាំ២០១២

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលបំណង

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌ និងលក្ខណវិនិច្ឆ័យលម្អិតសម្រាប់ការបណ្តុះបណ្តាលថ្នាក់បណ្ឌិត។

### ប្រការ ២.- គោលដៅ

ប្រកាសនេះមានគោលដៅដូចខាងក្រោម ៖

- រៀបចំសេចក្តីណែនាំលម្អិតពាក់ព័ន្ធនឹងការបណ្តុះបណ្តាលថ្នាក់បណ្ឌិត
- រៀបចំយន្តការត្រួតពិនិត្យគុណភាពបណ្តុះបណ្តាលថ្នាក់បណ្ឌិត
- ធ្វើឯកភាពនីយកម្មក្នុងការបណ្តុះបណ្តាលថ្នាក់បណ្ឌិត និងលើកកម្ពស់ការទទួលខុសត្រូវរបស់គ្រឹះស្ថានឧត្តមសិក្សា។

### ប្រការ ៣.- វិសាលភាពអនុវត្ត

ប្រកាសនេះមានវិសាលភាពអនុវត្តលើការបណ្តុះបណ្តាលថ្នាក់បណ្ឌិតនៅគ្រប់គ្រឹះស្ថានឧត្តមសិក្សាក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## លក្ខខណ្ឌសម្រាប់ការបណ្តុះបណ្តាលថ្នាក់បណ្ឌិត
## ផ្នែកទី១
## លក្ខខណ្ឌទូទៅ

### ប្រការ ៤.- លក្ខខណ្ឌបើកថ្នាក់បណ្ឌិត

គ្រឹះស្ថានឧត្តមសិក្សាមានសិទ្ធិបណ្តុះបណ្តាលថ្នាក់បណ្ឌិតបានក្នុងករណីដែលគ្រឹះស្ថានឧត្តមសិក្សានោះ មាននិស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដែលត្រូវមុខជំនាញយ៉ាងតិចមួយជំនាន់និងមានរបាយការណ៍បង្ហាញពីការរីកចម្រើននិងភាពចាំបាច់សម្រាប់ការបណ្តុះបណ្តាលថ្នាក់បណ្ឌិត។

គ្រឹះស្ថានឧត្តមសិក្សាត្រូវមានច្បាប់អនុញ្ញាតជាមុនពីក្រសួងអប់រំ យុវជន និងកីឡា ទើបមានសិទ្ធិជ្រើសរើសនិស្សិតនិងបណ្តុះបណ្តាលថ្នាក់បណ្ឌិត។

### ប្រការ ៥.- លក្ខខណ្ឌបណ្តុះបណ្តាល

គ្រឹះស្ថានឧត្តមសិក្សាដែលបណ្តុះបណ្តាលថ្នាក់បណ្ឌិតត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- មានរចនាសម្ព័ន្ធគ្រប់គ្រងទាំងរដ្ឋបាលនិងទាំងការសិក្សាដោយឡែក
- មានលិខិតបទដ្ឋានលម្អិតសម្រាប់ការបណ្តុះបណ្តាល
- មានការកំណត់មុខជំនាញច្បាស់លាស់សម្រាប់ស្នើសុំការបណ្តុះបណ្តាល
- មានកម្មវិធីសិក្សាលម្អិតតាមមុខជំនាញ
- មានការរៀបចំបុគ្គលិករដ្ឋបាល សាស្ត្រាចារ្យបង្រៀន និងសាស្ត្រាចារ្យណែនាំ
- មានមូលដ្ឋានសម្ភាររូបវន្ត និងហិរញ្ញវត្ថុសម្រាប់គាំទ្រការបណ្តុះបណ្តាល និង

មានលក្ខខណ្ឌផ្សេងៗមួយចំនួនទៀតដូចមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យលេខ ១៥១ អនក្រ.បក ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១០។

### ប្រការ ៦.- រចនាសម្ព័ន្ធគ្រប់គ្រង

គ្រឹះស្ថានឧត្តមសិក្សាត្រូវរៀបចំព្រឹទ្ធបុរសទទួលបន្ទុកថ្នាក់ក្រោយបរិញ្ញាបត្រ ដើម្បីរៀបចំគ្រប់គ្រង សម្របសម្រួល ត្រួតពិនិត្យ និងវាយតម្លៃរាល់សកម្មភាពនិងកម្មវិធីបណ្តុះបណ្តាល។

គ្រឹះស្ថានឧត្តមសិក្សាត្រូវបង្កើតក្រុមប្រឹក្សាវិទ្យាសាស្ត្រ គណៈកម្មការគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិត និងត្រូវរៀបចំក្រុមមុខជំនាញដើម្បីជួយព្រឹទ្ធបុរសទទួលបន្ទុកថ្នាក់ក្រោយបរិញ្ញាបត្រ។

ការគ្រប់គ្រងកម្មវិធីថ្នាក់ក្រោយបរិញ្ញាបត្រត្រូវមានការិយាល័យមួយចំនួនតាមការចាំបាច់។

## ផ្នែកទី២
## កម្មវិធីសិក្សានិងការបង្រៀន

### ប្រការ ៧.- រយៈពេលសិក្សា

គ្រឹះស្ថានឧត្តមសិក្សាត្រូវកំណត់ប្រភេទនិស្សិតថ្នាក់បណ្ឌិតសិក្សាពេញម៉ោង និងមិនពេញម៉ោង។ កម្មវិធីថ្នាក់បណ្ឌិតមានពីរប្រភេទ បណ្ឌិតស្រាវជ្រាវ និងបណ្ឌិតវិជ្ជាជីវៈ មានរយៈពេលសិក្សាពីបី(៣) ទៅប្រាំមួយ(៦)ឆ្នាំសម្រាប់ការសិក្សាពេញម៉ោង និងរហូតដល់ប្រាំបី(៨)ឆ្នាំសម្រាប់ការសិក្សាមិនពេញម៉ោង។ ចំនួនក្រេឌីតសិក្សាអប្បបរមាត្រូវមាន៥៤ក្រេឌីត និងត្រូវរៀបចំឱ្យសមមូលទៅនឹងទំហំការងារសិក្សានិងស្រាវជ្រាវ។

ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតត្រូវអនុវត្តជាសំខាន់ដោយវិធីស្វ័យសិក្សា និងស្រាវជ្រាវដោយមានការណែនាំ។

### ប្រការ ៨.- កម្មវិធីសិក្សាថ្នាក់បណ្ឌិតស្រាវជ្រាវ

កម្មវិធីសិក្សាថ្នាក់បណ្ឌិតស្រាវជ្រាវ ត្រូវបានបែងចែកជាតម្លៃអប្បបរមាទៅតាមក្រុមប្រភេទសិក្សាដូចខាងក្រោម៖

១. ការសិក្សាមុខវិជ្ជា៖

| | |
|---|---|
| - មុខវិជ្ជាបំពេញបន្ថែម | ៦ ក្រេឌីតសិក្សា |
| - មុខវិជ្ជាកម្រិតបណ្ឌិត | ៦ ក្រេឌីតសិក្សា |
| - មុខវិជ្ជាតម្រង់ទិសនិងការប្រឡងទូទៅ | ៩ ក្រេឌីតសិក្សា |

២. ការសរសេរនិងការពារនិក្ខេបបទ៖

| | |
|---|---|
| - ការពារគម្រោងស្រាវជ្រាវពិស្តារ | ៣ ក្រេឌីតសិក្សា |
| - ការចុះផ្សាយអត្ថបទស្រាវជ្រាវកម្រិតជាតិ ឬ កម្រិតអន្តរជាតិ | ៦ ក្រេឌីតសិក្សា |
| - ការចូលរួមវេទិកាវិទ្យាសាស្ត្រពាក់ព័ន្ធដោយមានធ្វើបទបង្ហាញ | ៣ ក្រេឌីតសិក្សា |
| - ការធ្វើសិក្ខាសាលាផ្ទាល់ខ្លួន | ៣ ក្រេឌីតសិក្សា |
| - និក្ខេបបទ | ១៨ ក្រេឌីតសិក្សា |
| សរុប | ៥៤ក្រេឌីតសិក្សា។ |

ការសិក្សាមុខវិជ្ជាតម្រង់ទិសនីមួយៗ ត្រូវមានឈ្មោះមុខវិជ្ជាតម្រង់ទិស គម្រោងខ្លឹមសារទូទៅសំខាន់ៗ សាស្ត្រាចារ្យណែនាំវិទ្យាសាស្ត្រ និងផែនការអនុវត្ត។

### ប្រការ ៩.- កម្មវិធីសិក្សាថ្នាក់បណ្ឌិតវិជ្ជាជីវៈ

កម្មវិធីសិក្សាថ្នាក់បណ្ឌិតវិជ្ជាជីវៈ ត្រូវបានបែងចែកជាតម្លៃអប្បបរមាទៅតាមក្រុមប្រភេទសិក្សាដូចខាងក្រោម៖

១. ការសិក្សាមុខវិជ្ជា៖

| | |
|---|---|
| - មុខវិជ្ជាបំពេញបន្ថែម | ៦ ក្រេឌីតសិក្សា |

| | |
|---|---|
| - មុខវិជ្ជាកម្រិតបណ្ឌិត | ១៥ ក្រេឌីតសិក្សា |
| - សារណាបទពិសោធវិជ្ជាជីវៈ | ៦ ក្រេឌីតសិក្សា |
| ២. និក្ខេបបទ៖ | |
| - ការពារគម្រោងស្រាវជ្រាវពិស្តារ | ៣ ក្រេឌីតសិក្សា |
| - ការចុះផ្សាយអត្ថបទស្រាវជ្រាវកម្រិតជាតិ ឬ កម្រិតអន្តរជាតិ | ៦ ក្រេឌីតសិក្សា |
| - ការចូលរួមវេទិកាវិទ្យាសាស្ត្រពាក់ព័ន្ធដោយមានធ្វើបទបង្ហាញ | ៣ ក្រេឌីតសិក្សា |
| - ការធ្វើសិក្ខាសាលាផ្ទាល់ខ្លួន | ៣ ក្រេឌីតសិក្សា |
| - និក្ខេបបទ | ១២ ក្រេឌីតសិក្សា |
| សរុប | ៥៤ក្រេឌីតសិក្សា។ |

**ប្រការ ១០.- មុខវិជ្ជាបំពេញបន្ថែម**

ការសិក្សាមុខវិជ្ជាបំពេញបន្ថែម ត្រូវធ្វើឡើងនៅដើមឆ្នាំសិក្សាដំបូង។ មុខវិជ្ជាបំពេញបន្ថែមសម្រាប់បេក្ខជនបណ្ឌិត ត្រូវសម្រេចដោយគណៈកម្មការគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិតតាមសំណើរបស់ក្រុមមុខជំនាញ។

ចាត់ទុកថាទទួលបានជោគជ័យលើគ្រប់មុខវិជ្ជាសិក្សាទាំងអស់លុះត្រាតែមិនមានពិន្ទុមុខវិជ្ជាណាមួយទាបជាង៧០ភាគរយនៃពិន្ទុសរុបជាដាច់ខាត។

**ប្រការ ១១.- មុខវិជ្ជាកម្រិតបណ្ឌិត**

ការសិក្សាមុខវិជ្ជាកម្រិតបណ្ឌិតត្រូវមានមុខវិជ្ជារួម និងមុខវិជ្ជាមុខជំនាញដែលត្រូវបានអនុវត្តនៅក្នុងឆ្នាំសិក្សាទី១ និងអាចបន្តទៅឆ្នាំសិក្សាទី២។

**ប្រការ ១២.- ខ្លឹមសារមុខវិជ្ជា**

កម្មវិធីសិក្សាថ្នាក់បណ្ឌិតតាមជំនាញនីមួយៗ ត្រូវមានការយល់ព្រមពីក្រសួងអប់រំ យុវជន និងកីឡា។ កម្មវិធីសិក្សានៃមុខជំនាញនីមួយៗ ត្រូវមានគោលបំណង ការពិពណ៌នា និងរចនាសម្ព័ន្ធរួមនៃមុខវិជ្ជានីមួយៗ។ មុខវិជ្ជានីមួយៗនៃកម្មវិធីសិក្សា ត្រូវមានគោលបំណង ការពិពណ៌នាអំពីមុខវិជ្ជា និងចំនួនក្រេឌីត។

## ផ្នែកទី៣
## បុគ្គលិករដ្ឋបាល និងសាស្ត្រាចារ្យបង្រៀន

**ប្រការ ១៣.- គោលការណ៍ជ្រើសរើស**

គ្រឹះស្ថានឧត្តមសិក្សាត្រូវមានគោលការណ៍ជ្រើសរើស អភិវឌ្ឍបុគ្គលិករដ្ឋបាល សាស្ត្រាចារ្យបង្រៀន សាស្ត្រាចារ្យណែនាំគោល សហសាស្ត្រាចារ្យណែនាំ និងសាស្ត្រាចារ្យណែនាំរង ដែលមានគុណវុឌ្ឍិច្បាស់លាស់តាមឧបសម្ព័ន្ធនៃប្រកាសនេះ។

### ប្រការ ១៤.- ចំនួនសាស្ត្រាចារ្យ

គ្រឹះស្ថានឧត្តមសិក្សាត្រូវមានសាស្ត្រាចារ្យបង្រៀនពេញម៉ោងសមាមាត្រនឹងចំនួនបេក្ខជនបណ្ឌិត។ គ្រឹះស្ថានឧត្តមសិក្សាបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត ត្រូវបញ្ជូនបញ្ជីឈ្មោះសាស្ត្រាចារ្យបង្រៀន សាស្ត្រាចារ្យណែនាំគោល សហសាស្ត្រាចារ្យណែនាំ សាស្ត្រាចារ្យណែនាំរងទាំងអស់ មកនាយកដ្ឋានជំនាញនៃក្រសួងអប់រំ យុវជន និងកីឡានៅរៀងរាល់ដើមឆ្នាំសិក្សា។

### ប្រការ ១៥.- ការចាត់តាំងសាស្ត្រាចារ្យ

ការចាត់តាំងសាស្ត្រាចារ្យណែនាំគោល ត្រូវសមស្របទៅនឹងជំនាញសិក្សារបស់និស្សិត ហើយតួនាទីនេះមានសុពលភាពក្នុងពេលសិក្សារបស់និស្សិត លើកលែងតែមានការកំណត់ដោយឡែក។ ការរៀបចំចាត់តាំងនេះត្រូវគិតដល់ករណីសាស្ត្រាចារ្យណែនាំគោលអវត្តមានរយៈពេលយូរ ការសុំលាលែងពីតំណែង ឬការចូលនិវត្តន៍។

### ប្រការ ១៦.- ក្រុមសាស្ត្រាចារ្យណែនាំ

បេក្ខជនបណ្ឌិតម្នាក់ៗត្រូវដឹកនាំដោយគណៈកម្មការសាស្ត្រាចារ្យណែនាំមួយ ដែលមានសមាជិកបី(៣)រូបគឺ ប្រធានមួយរូបជាសាស្ត្រាចារ្យណែនាំគោល និងសាស្ត្រាចារ្យណែនាំរង ឬសហសាស្ត្រាចារ្យណែនាំចំនួនពីរ(២)រូបទៀតជាសមាជិក ដែលជាសាស្ត្រាចារ្យនៅក្នុង ឬ ក្រៅស្ថាប័នបណ្ដុះបណ្ដាលក្នុងឬក្រៅប្រទេស។

## ផ្នែកទី៤
## ឯកសារស្នើសុំបណ្ដុះបណ្ដាល

### ប្រការ ១៧.- សំណុំឯកសារ

គ្រឹះស្ថានឧត្តមសិក្សាត្រូវដាក់សំណុំឯកសារស្នើសុំបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត មកក្រសួងអប់រំ យុវជន និងកីឡាចំនួនពីរច្បាប់។ សំណុំឯកសារស្នើសុំនេះ មានដូចខាងក្រោម៖

- លិខិតស្នើសុំបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត ដោយបញ្ជាក់ឱ្យបានច្បាស់លាស់ពីគោលបំណង និងមុខជំនាញឯកទេសបណ្ដុះបណ្ដាល
- វិញ្ញាបនបត្រទទួលស្គាល់គុណភាពអប់រំរបស់គ្រឹះស្ថានឧត្តមសិក្សាចេញដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (គ.ទ.ក)
- ឯកសារអភិបាលកិច្ចនិងការគ្រប់គ្រង ដោយភ្ជាប់មកជាមួយនូវរចនាសម្ព័ន្ធគ្រប់គ្រង លិខិតបទដ្ឋានផ្សេងៗ និងបទបញ្ជាផ្ទៃក្នុងដែលពាក់ព័ន្ធ
- ប្រវត្តិរូបរបស់សាកលវិទ្យាធិការ នាយក ព្រឹទ្ធបុរស ប្រធានក្រុមមុខជំនាញ និងប្រធានការិយាល័យ ដោយបញ្ជាក់ពីកម្រិតសញ្ញាបត្រ មុខជំនាញ បទពិសោធការងារ និងភ្ជាប់មកជាមួយនូវសន្លឹកសញ្ញាបត្រថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
- កម្មវិធីសិក្សាលម្អិតតាមមុខជំនាញឯកទេស

- របាយការណ៍ស្ដីពីធនធាននិងមូលដ្ឋានសម្ភាររូបវន្តសម្រាប់ទ្រទ្រង់ដំណើរការបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត
- លក្ខខណ្ឌនៃការជ្រើសរើសសាស្ត្រាចារ្យណែនាំគោល សហសាស្ត្រាចារ្យណែនាំ សាស្ត្រាចារ្យណែនាំរង
- បញ្ជីរាយនាមបុគ្គលិក សាស្ត្រាចារ្យ ដោយបញ្ជាក់ពីកម្រិតសញ្ញាបត្រ មុខជំនាញ បទពិសោធការងារ និងភ្ជាប់មកជាមួយនូវប្រវត្តិរូប សន្លឹកសញ្ញាបត្រថតចម្លងត្រឹមត្រូវតាមច្បាប់ដើម និងកិច្ចសន្យាការងារជាមួយគ្រឹះស្ថាន
- ផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពប្រចាំឆ្នាំក្នុងការបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត
- លក្ខខណ្ឌនៃការជ្រើសរើសនិស្សិតឱ្យចូលសិក្សា និងបញ្ចប់ការសិក្សាថ្នាក់បណ្ឌិត និង
- លក្ខខណ្ឌនិងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងៗទៀត។

## ផ្នែកទី៥
## ការស្នើសុំបណ្ដុះបណ្ដាលមុខជំនាញបន្ថែម

### ប្រការ ១៨.- មុខជំនាញបន្ថែម

ការស្នើសុំបណ្ដុះបណ្ដាលមុខជំនាញបន្ថែម ត្រូវគោរពតាមលក្ខខណ្ឌនិងលក្ខណវិនិច្ឆ័យលម្អិតដែលមានចែងក្នុងប្រកាសនេះ។ សំណុំឯកសារស្នើសុំបណ្ដុះបណ្ដាលមុខជំនាញបន្ថែម ត្រូវរៀបចំឱ្យស្របទៅនឹងខ្លឹមសារដែលមានចែងក្នុងប្រការ១៧ ខាងលើនេះ។

## ជំពូកទី៣
## លក្ខខណ្ឌនិងលក្ខណវិនិច្ឆ័យសម្រាប់ការជ្រើសរើសនិស្សិត

### ប្រការ ១៩.- រូបភាពជ្រើសរើស

គ្រឹះស្ថានឧត្ដមសិក្សាអាចជ្រើសរើសនិស្សិតឱ្យចូលសិក្សាបានតែមួយដងគត់ក្នុងមួយឆ្នាំសិក្សា។

ការប្រឡងជ្រើសរើសត្រូវធ្វើឡើងតាមការពិនិត្យសំណុំឯកសារ ការសម្ភាសន៍ និងវាយតម្លៃលើសំណើគម្រោងស្រាវជ្រាវបឋមដោយផ្ទាល់។

### ប្រការ ២០.- លក្ខខណ្ឌសម្រាប់ការជ្រើសរើស

ការចូលសិក្សាថ្នាក់បណ្ឌិត និស្សិតត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

- បានឆ្លងកាត់ការសិក្សាគ្រប់ភូមិសិក្សា ដែលមានលក្ខណៈជាប្រព័ន្ធនិងប្រក្រតី
- ទទួលបានពិន្ទុមធ្យមភាគសរុប(GPA)ចាប់ពី ៣.០០ឡើងទៅ ឬនិស្សិតសរសេរនិក្ខេបបទក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់
- មានសំណើគម្រោងស្រាវជ្រាវបឋមច្បាស់លាស់
- មានសមត្ថភាពភាសាអន្តរជាតិណាមួយទៅតាមការកំណត់របស់កម្មវិធី និង
- មានមូលដ្ឋានគ្រឹះព័ត៌មានវិទ្យាសម្រាប់ប្រើប្រាស់ក្នុងការស្រាវជ្រាវ។

ចំនួននិស្សិតចូលសិក្សាអាស្រ័យទៅលើសមត្ថភាពនិងលទ្ធភាពធនធានរបស់គ្រឹះស្ថានឧត្តមសិក្សា។ សាស្ត្រាចារ្យម្នាក់មិនអាចមាននិស្សិតក្នុងបន្ទុកណែនាំលើសពី៤(ប្រាំបួន)រូបឡើយ។

**ប្រការ ២១.- ការផ្សព្វផ្សាយព័ត៌មានជ្រើសរើស**

គ្រឹះស្ថានឧត្តមសិក្សា ត្រូវរៀបចំផែនការជ្រើសរើសនិស្សិត និងផ្សព្វផ្សាយព័ត៌មានជ្រើសរើសឱ្យបានទូលំទូលាយយ៉ាងតិចបី(៣)ខែមុនកាលបរិច្ឆេទប្រឡងជ្រើសរើស រួចត្រូវធ្វើរបាយការណ៍ជូនទៅក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ ២២.- សំណុំលិខិតបេក្ខជន**

បេក្ខជនត្រូវមានសំណុំលិខិតដូចខាងក្រោម៖

- ប្រវត្តិរូបសង្ខេបរបស់បេក្ខជន មួយ(១)ច្បាប់
- ពាក្យចុះឈ្មោះចូលរៀនរបស់បេក្ខជន មួយ(១)ច្បាប់
- លិខិតបិទជិតរបស់អ្នកផ្តល់យោបល់បី(៣)រូប (អ្នកគ្រប់គ្រង១រូប និងសាស្ត្រាចារ្យធ្លាប់ណែនាំ២រូប)
- ច្បាប់ថតចម្លងសញ្ញាបត្របរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ (ដោយមានការបញ្ជាក់ពីសាលារាជធានី ឬ សាលាខេត្ត ឬ សាលាក្រុង ស្រុក ខណ្ឌមានសមត្ថកិច្ច)
- ព្រឹត្តិបត្រពិន្ទុដែលបានសិក្សានៅថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ មួយ(១)ច្បាប់
- វិញ្ញាបនបត្របញ្ជាក់កម្រិតភាសាអង់គ្លេស ឬ ភាសាអន្តរជាតិណាមួយដែលអាចទទួលស្គាល់បាន
- វិញ្ញាបនបត្របញ្ជាក់កម្រិតមូលដ្ឋានគ្រឹះព័ត៌មានវិទ្យាសម្រាប់ការស្រាវជ្រាវដែលអាចទទួលស្គាល់បាន
- សំណើគម្រោងស្រាវជ្រាវបឋម។

**ប្រការ ២៣.- តម្រូវការភាសាបរទេសនិងមូលដ្ឋានគ្រឹះព័ត៌មានវិទ្យាសម្រាប់ការស្រាវជ្រាវ**

ក. តម្រូវការកម្រិតភាសាបរទេស

ក១. នៅពេលដាក់សំណុំលិខិតសុំជ្រើសរើស បេក្ខជនបណ្ឌិតត្រូវមានវិញ្ញាបនបត្រ ឬ សញ្ញាបត្រភាសាបរទេសតាមលក្ខខណ្ឌណាមួយដូចខាងក្រោម៖

- មានបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ពីប្រទេសក្រៅដែលប្រើភាសាអង់គ្លេសក្នុងការបណ្តុះបណ្តាល ឬ ភាសាបរទេសណាមួយទៀតសមស្របទៅនឹងតម្រូវការរបស់មុខជំនាញបណ្តុះបណ្តាលតាមការសម្រេចរបស់ក្រុមប្រឹក្សាវិទ្យាសាស្ត្រ ឬ
- មានបរិញ្ញាបត្រនិងបរិញ្ញាបត្រជាន់ខ្ពស់នៅក្នុងប្រទេស ដែលភាសាប្រើប្រាស់ក្នុងការបណ្តុះបណ្តាលជាភាសាអង់គ្លេសមិនឆ្លងកាត់អ្នកបកប្រែ ឬ ភាសាបរទេសណាមួយសមស្របទៅនឹងតម្រូវការមុខជំនាញបណ្តុះបណ្តាល តាមការសម្រេចរបស់ក្រុមប្រឹក្សាវិទ្យាសាស្ត្រ ឬ

- មានបរិញ្ញាបត្រភាសាអង់គ្លេស ឬភាសាអន្តរជាតិណាមួយសមស្របទៅនឹងតម្រូវការមុខជំនាញបណ្តុះបណ្តាលតាមការសម្រេចរបស់ក្រុមប្រឹក្សាវិទ្យាសាស្ត្រ ឬ
- មានវិញ្ញាបនបត្រភាសាអង់គ្លេសTOEFL IBT ៦១ពិន្ទុ ឬTOEFL ៥០០ពិន្ទុ ឬTOEFL ITP ៥០០ពិន្ទុ ឬ IELTS ៥.០ឡើងទៅឬសមមូល ឬ
- មានកម្រិតភាសាអង់គ្លេសតាមរយៈការធ្វើតេសដែលរៀបចំដោយគ្រឹះស្ថានឧត្តមសិក្សា និងទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា។

ក២. កម្រិតភាសាបរទេសដទៃទៀតសមមូលត្រូវបានកំណត់តាមភាពជាក់ស្តែងនិងទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា។

ខ. កម្រិតប្រើប្រាស់មូលដ្ឋានបច្ចេកវិទ្យាព័ត៌មានសម្រាប់ការស្រាវជ្រាវ

ត្រូវមានសមត្ថភាពប្រើប្រាស់មូលដ្ឋានគ្រឹះព័ត៌មានវិទ្យាសម្រាប់ការស្រាវជ្រាវ (Word, Excel, PowerPoint និង Internet search)។

## **ប្រការ ២៤.- ការរៀបចំយន្តការប្រឡងជ្រើសរើស**

គ្រឹះស្ថានឧត្តមសិក្សាត្រូវសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបង្កើតគណៈកម្មការប្រឡងជ្រើសរើសដែលមានសមាសភាពដូចខាងក្រោម៖

- គណៈកម្មការពិនិត្យនិងសម្រេចលទ្ធផលចុងក្រោយ
- គណៈមេប្រយោគ

គណៈកម្មការប្រឡងជ្រើសរើសនេះមានសិទ្ធិបង្កើតគណៈកម្មការកណ្តាល អនុគណៈកម្មការមុខជំនាញ និងអនុគណៈកម្មការផ្សេងៗទៀតតាមតម្រូវការចាំបាច់ ដើម្បីឱ្យដំណើរការប្រឡងជ្រើសរើសប្រព្រឹត្តទៅដោយប្រសិទ្ធភាពនិងមានតម្លាភាព។ តួនាទីនិងភារកិច្ចគណៈកម្មការកណ្តាល អនុគណៈកម្មការមុខជំនាញ និងអនុគណៈកម្មការផ្សេងទៀត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួងអប់រំ យុវជន និងកីឡា។

## **ប្រការ ២៥.- យន្តការជ្រើសរើស**

ការប្រឡងជ្រើសរើសនិស្សិតថ្នាក់បណ្ឌិតត្រូវធ្វើឡើងជាពីរជំហាន។ ជំហានទីមួយ ត្រូវធ្វើឡើងដោយការពិនិត្យសំណុំលិខិតបេក្ខជន និងជំហានទីពីរ គឺការវាយតម្លៃលើការឡើងបង្ហាញសំណើស្រាវជ្រាវបឋមរបស់បេក្ខជន។

ដោយឡែកសម្រាប់បេក្ខជនបណ្ឌិតវិជ្ជាជីវៈ ជំហានទីមួយត្រូវពិនិត្យនិងវាយតម្លៃទៅលើសំណុំឯកសារបេក្ខជន ស្រង់ស្ថិតិបទពិសោធវិជ្ជាជីវៈនិងការធ្លាប់បោះពុម្ពផ្សាយ និងពិនិត្យគម្រោងស្រាវជ្រាវបឋមរបស់បេក្ខជន និងជំហានទីពីរ ត្រូវឡើងបង្ហាញសំណើគម្រោងការណ៍ស្រាវជ្រាវបែបសកម្មភាពរបស់បេក្ខជន។

**ប្រការ ២៦.- ការប្រកាសលទ្ធផលជ្រើសរើស**

គណៈកម្មការប្រឡងជ្រើសរើសត្រូវរៀបចំរបាយការណ៍ និងលទ្ធផលនៃការប្រឡងជ្រើសរើស ដើម្បីជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ពិនិត្យនិងសម្រេច។

**ប្រការ ២៧.- ការរក្សាទុកសំណុំឯកសារ**

គ្រឹះស្ថានឧត្តមសិក្សាត្រូវទទួលខុសត្រូវនិងរៀបចំបញ្ជីឈ្មោះនិស្សិតថ្នាក់បណ្ឌិតដោយផ្អែកលើលទ្ធផលនៃការជ្រើសរើស និងរៀបចំសំណុំឯកសាររបស់និស្សិតម្នាក់ៗ រួមមានការត្រួតពិនិត្យឡើងវិញ ការឱ្យបំពេញបន្ថែម ការរក្សាទុក និងការសន្សំបន្ថែមជាទៀងទាត់តាមការកំណត់របស់គ្រឹះស្ថានឧត្តមសិក្សា។

**ប្រការ ២៨.- ការរៀបចំបវេសនកាល**

គ្រឹះស្ថានឧត្តមសិក្សាដែលបណ្តុះបណ្តាលថ្នាក់បណ្ឌិត ត្រូវរៀបចំបវេសនកាលជាទៀងទាត់ក្នុងមួយឆ្នាំម្តងនិងជាផ្លូវការ។ បន្ទាប់ពីបវេសនកាល ត្រូវរៀបចំបែងចែកនិស្សិតជ្រើសរើសថ្មីបញ្ចូលទៅតាមក្រុមមុខជំនាញនីមួយៗ ដើម្បីហ្វឹកហាត់ការងារផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រជាមួយក្រុមវិជ្ជាជីវៈដូចគ្នា។

## ជំពូកទី៤
## លក្ខខណ្ឌនិងលក្ខណៈវិនិច្ឆ័យសម្រាប់បញ្ចប់ការសិក្សា
### ផ្នែកទី១
### ការគ្រប់គ្រងការងារបណ្តុះបណ្តាល

**ប្រការ ២៩.- ការគ្រប់គ្រងព័ត៌មានសិក្សា**

គ្រឹះស្ថានឧត្តមសិក្សានីមួយៗត្រូវទទួលខុសត្រូវលើការគ្រប់គ្រងព័ត៌មានសិក្សា។

គ្រឹះស្ថានឧត្តមសិក្សានីមួយៗ ត្រូវផ្តល់ប្រធានបទស្រាវជ្រាវ និងក្រុមសាស្ត្រាចារ្យណែនាំរបស់បេក្ខជនបណ្ឌិតម្នាក់ៗទៅក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ ៣០.- គណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃនិក្ខេបបទ**

គ្រឹះស្ថានឧត្តមសិក្សាបណ្តុះបណ្តាលថ្នាក់បណ្ឌិតត្រូវរៀបចំឱ្យមានគណៈកម្មការនានាដូចខាងក្រោម ៖

ក. គណៈកម្មការការពារគម្រោងពិស្តារដែលនៅក្នុងនោះមានសមាសភាពប្រាំ(៥)រូប ដឹកនាំដោយសាស្ត្រាចារ្យណែនាំគោល។ ក្រុមសាស្ត្រាចារ្យណែនាំទាំងអស់ជាសមាជិក និងសមាសភាពពីរ(២)រូបទៀត មានបទពិសោធស្រាវជ្រាវក្នុងមុខជំនាញពាក់ព័ន្ធទៅនឹងប្រធានបទនិក្ខេបបទ។

ខ. គណៈកម្មការការពារនិក្ខេបបទសាកល្បងមានសមាសភាពប្រាំពីរ(៧)រូប ដែលក្នុងនោះមានសាស្ត្រាចារ្យវាយតម្លៃបី(៣)រូបដែលជាអ្នកមានជំនាញដូចទៅនឹងប្រធានបទនិក្ខេបបទ និងមិនមែនជាសមាជិកក្រុមសាស្ត្រាចារ្យណែនាំ ក្នុងនោះពីរ(២)រូបត្រូវតែជាអ្នកជំនាញមកពីក្រៅគ្រឹះស្ថានឧត្តមសិក្សា។ សមាជិកក្រុមសាស្ត្រាចារ្យណែនាំមួយចំនួនអាចជាសមាជិកនៃគណៈកម្មការនេះ។

គ. គណៈកម្មការពិនិត្យនិងវាយតម្លៃនិក្ខេបបទឯករាជ្យ មានសមាសភាពចំនួនបី(៣)រូប មួយ(១)រូបជាអ្នកវាយតម្លៃរបស់គ្រឹះស្ថានឧត្តមសិក្សា និងពីរ(២)រូបទៀតជាអ្នកវាយតម្លៃមកពីខាងក្រៅ។

ឃ. គណៈកម្មការវាយតម្លៃនិក្ខេបបទបញ្ចប់មានសមាសភាពប្រាំពីរ(៧)រូប មានប្រធានមួយ(១)រូប លេខាកត់ត្រាមួយ(១)រូប គណៈកម្មការពិនិត្យនិងវាយតម្លៃនិក្ខេបបទឯករាជ្យបី(៣)រូប សាស្ត្រាចារ្យណែនាំគោលមួយ(១)រូប និងសមាជិកមួយ(១)រូបទៀតដែលមិនមែនជាសហសាស្ត្រាចារ្យ ឬសាស្ត្រាចារ្យណែនាំរង ឬអ្នកដែលមិនអាចជាសាច់ញាតិ មិត្តភក្តិ ឬអ្នករួមការងារជិតដិតនឹងបេក្ខជន។ សមាសភាពគណៈកម្មការនេះត្រូវសម្រេចដោយក្រសួងអប់រំ យុវជន និងកីឡា តាមការស្នើសុំរបស់គ្រឹះស្ថានឧត្តមសិក្សា។

ង. គណៈកម្មការដោះស្រាយទំនាស់។

**ប្រការ ៣១.- ភារកិច្ចរបស់បេក្ខជនបណ្ឌិត**

បេក្ខជនបណ្ឌិតត្រូវមានកាតព្វកិច្ចដូចខាងក្រោម ៖

- បញ្ចប់ដោយជោគជ័យគ្រប់មុខវិជ្ជាសិក្សា គ្រប់ជំហាននៃដំណើរការបណ្ដុះបណ្ដាលមុនពេលប្រគល់និក្ខេបបទ
- ផ្ដល់គ្រប់ព័ត៌មានចាំបាច់ដល់ផ្នែករដ្ឋបាលនៃគ្រឹះស្ថានឧត្តមសិក្សាតាមតម្រូវការ
- រៀបចំផែនការសកម្មភាពនិងមានការព្រមព្រៀងជាមួយក្រុមសាស្ត្រាចារ្យណែនាំ
- គោរពតាមក្រមសីលធម៌ស្រាវជ្រាវ និងមិនលួចចម្លងស្នាដៃពីអ្នកដទៃ
- ត្រូវសរសេរនិក្ខេបបទដោយផ្ទាល់ និងបំពេញតាមតម្រូវការនៃគំរូរួមដែលបានកំណត់ដូចមានចែងក្នុងប្រការ៣៣ នៃប្រកាសនេះ។

**ប្រការ ៣២.- ការផ្លាស់ប្ដូរនៅក្នុងពេលដំណើរការបណ្ដុះបណ្ដាល**

និស្សិតមានសិទ្ធិសុំផ្លាស់ប្ដូរប្រធានបទ បន្ថែមឬប្ដូរសាស្ត្រាចារ្យណែនាំ ព្យួរការសិក្សា និងផ្ទេរការសិក្សាតាមគោលការណ៍ និងបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថានឧត្តមសិក្សា។

## ផ្នែកទី២

## ការរៀបចំការការពារនិងការវាយតម្លៃនិក្ខេបបទ

**ប្រការ ៣៣.- ការរៀបចំនិក្ខេបបទបណ្ឌិត**

គ្រឹះស្ថានឧត្តមសិក្សា ត្រូវកំណត់ទម្រង់គំរូរួមមួយអំពីនិក្ខេបបទដែលត្រូវសរសេរទៅតាមជំនាញនីមួយៗឱ្យមានលក្ខណៈវិទ្យាសាស្ត្រតាមស្តង់ដារជាតិ និងអន្តរជាតិ។ ទម្រង់គំរូរួមនិក្ខេបបទនេះ ត្រូវមានការយល់ព្រមពីក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ ៣៤.- ការវាយតម្លៃនិក្ខេបបទ**

ការវាយតម្លៃនិក្ខេបបទត្រូវធ្វើឡើងបន្តបន្ទាប់តាមលំដាប់លំដោយដូចខាងក្រោម ៖

- ការវាយតម្លៃគម្រោងស្រាវជ្រាវពិស្តារ
- ការវាយតម្លៃនិក្ខេបបទសាកល្បង

- ការវាយតម្លៃនិក្ខេបបទដោយគណៈកម្មការពិនិត្យនិងវាយតម្លៃឯកភាព ការវាយតម្លៃការការពារនិក្ខេបបទបញ្ចប់។

**ប្រការ ៣៥.- ការការពារគម្រោងស្រាវជ្រាវពិស្តារ**

និស្សិតត្រូវការពារគម្រោងស្រាវជ្រាវពិស្តារជាផ្លូវការ និងជាសាធារណៈនៅចំពោះមុខគណៈកម្មការដែលរៀបចំដោយគ្រឹះស្ថានឧត្តមសិក្សា។

**ប្រការ ៣៦.- ការការពារនិក្ខេបបទសាកល្បង**

និស្សិតត្រូវការពារនិក្ខេបបទសាកល្បង និងជាសាធារណៈនៅចំពោះមុខគណៈកម្មការដែលផ្អែកតាមសំណើសុំរបស់សាមីខ្លួន និងមានការយល់ព្រមពីក្រុមសាស្ត្រាចារ្យណែនាំ ដែលរៀបចំដោយគ្រឹះស្ថានឧត្តមសិក្សា។

**ប្រការ ៣៧.- ការការពារនិក្ខេបបទបញ្ចប់**

គ្រឹះស្ថានឧត្តមសិក្សា ត្រូវបញ្ជូនសំណុំលិខិតរបស់បេក្ខជនបណ្ឌិតមកក្រសួងអប់រំ យុវជន និងកីឡា ដើម្បីស្នើសុំការពារនិក្ខេបបទបញ្ចប់។

និស្សិតត្រូវការពារនិក្ខេបបទបញ្ចប់ជាផ្លូវការ និងជាសាធារណៈនៅចំពោះមុខគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទបញ្ចប់ ដែលស្នើឡើងដោយគ្រឹះស្ថានឧត្តមសិក្សា និងមានការយល់ព្រមពីក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ ៣៨.- ការការពារនិក្ខេបបទឡើងវិញ**

បេក្ខជនបណ្ឌិតដែលពុំទទួលបានជោគជ័យក្នុងការការពារនិក្ខេបបទបញ្ចប់ ត្រូវបានអនុញ្ញាតឱ្យការពារនិក្ខេបបទឡើងវិញ តាមលក្ខខណ្ឌដូចខាងក្រោម៖

- បេក្ខជនបណ្ឌិតត្រូវកែសម្រួលនិក្ខេបបទឡើងវិញ ហើយដាក់ស្នើសុំការពារជាលើកទីពីរយ៉ាងយូរបំផុតត្រឹម២៤ខែ គិតចាប់ពីថ្ងៃដែលបានការពារលើកទីមួយ
- សមាសភាពគណៈកម្មការវាយតម្លៃនិក្ខេបបទឡើងវិញ ត្រូវដូចគ្នាទៅនឹងសមាសភាពគណៈកម្មការវាយតម្លៃនិក្ខេបបទបញ្ចប់ដែរ។ ករណីមានសមាជិកគណៈកម្មការណាមួយអវត្តមាន គ្រឹះស្ថានឧត្តមសិក្សាត្រូវស្នើឈ្មោះសុំមកក្រសួងអប់រំ យុវជន និងកីឡាដើម្បីបំពេញជំនួស
- មិនអនុញ្ញាតឱ្យការពារនិក្ខេបបទជាលើកទីបី។

**ប្រការ ៣៩.- លក្ខខណ្ឌសម្រាប់អនុញ្ញាតឱ្យការពារនិក្ខេបបទបញ្ចប់**

និស្សិតត្រូវបំពេញគ្រប់លក្ខខណ្ឌ ដើម្បីទទួលបានការអនុញ្ញាតឱ្យការពារនិក្ខេបបទបញ្ចប់ ដូចខាងក្រោម៖

- និស្សិតត្រូវបញ្ចប់ដោយជោគជ័យគ្រប់មុខវិជ្ជាសិក្សានៅចុងដំណាក់កាលទីមួយ ហើយប្រគល់និក្ខេបបទសម្រាប់ការវាយតម្លៃ

- និស្សិតត្រូវផ្តល់កាលបរិច្ឆេទនៃការបញ្ចប់ដោយជោគជ័យ និងលទ្ធផលវាយតម្លៃនីមួយៗសម្រាប់គ្រប់មុខវិជ្ជាសិក្សានិងការប្រឡងទូទៅ ការចូលរួមសិក្ខាសាលានិងការធ្វើសិក្ខាសាលាឱ្យគ្រប់តាមចំនួនកំណត់ហើយនិងការចុះផ្សាយអត្ថបទស្រាវជ្រាវកម្រិតជាតិឬកម្រិតអន្តរជាតិយ៉ាងហោចណាស់ឱ្យបានរយៈពេល៤(បួន)ខែមុនការឡើងការពារនិក្ខេបបទបញ្ចប់។

និក្ខេបបទត្រូវបានគាំទ្រដោយគណៈកម្មការពិនិត្យនិងវាយតម្លៃឯកភាពដោយសំឡេងភាគច្រើន។

## ផ្នែកទី៣

## ការពិនិត្យនិក្ខេបបទនិងការប្រគល់សញ្ញាបត្រ

### ប្រការ ៤០.- ការបញ្ជូនលទ្ធផលបញ្ចប់

គ្រឹះស្ថានឧត្តមសិក្សា ត្រូវបញ្ជូនរបាយការណ៍ស្តីពីការការពារនិក្ខេបបទបញ្ចប់ និងនិក្ខេបបទរបស់បេក្ខជនបណ្ឌិតយ៉ាងយូរមួយខែក្រោយពេលគណៈកម្មការសម្រេចឱ្យបេក្ខជនជាប់ជាស្ថាពរមកក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិនិត្យនិងសម្រេចផ្តល់សញ្ញាបត្រ។

### ប្រការ ៤១.- ការផ្តល់សញ្ញាបត្រ

ក្រសួងអប់រំ យុវជន និងកីឡា ពិនិត្យនិងផ្តល់សញ្ញាបត្របណ្ឌិតដល់បេក្ខជនដែលបានការពារនិក្ខេបបទបញ្ចប់ដោយជោគជ័យ តាមសំណើរបស់គ្រឹះស្ថានឧត្តមសិក្សា។

## ផ្នែកទី៤

## នីតិវិធីដោះស្រាយទំនាស់និងការពិន័យ

### ប្រការ ៤២.- ការដោះស្រាយទំនាស់

ករណីមានពាក្យបណ្តឹងឬការតវ៉ា គ្រឹះស្ថានឧត្តមសិក្សាត្រូវដោះស្រាយតាមរយៈសាស្ត្រាចារ្យណែនាំគោល ក្រុមប្រឹក្សាវិទ្យាសាស្ត្រ និងគណៈគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា។

ករណីគ្រឹះស្ថានឧត្តមសិក្សាពុំអាចដោះស្រាយបាន ត្រូវបញ្ជូនសំណុំរឿងមកឱ្យក្រសួងអប់រំ យុវជន និងកីឡា ជាអ្នកដោះស្រាយចុងក្រោយ។

### ប្រការ ៤៣.- ការពិន័យ

បេក្ខជនដែលផ្តល់ព័ត៌មានមិនត្រឹមត្រូវនៅក្នុងសំណុំលិខិតផ្ទាល់ខ្លួន នៅពេលដាក់ពាក្យសុំចូលសិក្សា ត្រូវលុបឈ្មោះចេញពីបញ្ជីបេក្ខជន។ ក្នុងករណីរកឃើញនៅក្រោយពេលចូលរៀន ត្រូវលុបឈ្មោះចេញពីបញ្ជីបេក្ខជនបណ្ឌិត។ ក្នុងករណីបានការពារនិក្ខេបបទបញ្ចប់ដោយជោគជ័យ ក្រសួងត្រូវប្រកាសជាមោឃភាពនូវលទ្ធផលនេះ។

ការលួចចម្លងស្នាដៃរបស់អ្នកដទៃត្រូវចាត់ទុកជាបទល្មើសសម្រាប់អ្នកស្រាវជ្រាវ ហើយត្រូវបញ្ឈប់បេក្ខភាពបណ្ឌិត ឬ ដកហូតសញ្ញាបត្រក្នុងករណីរកឃើញនៅពេលក្រោយ។

## ជំពូកទី៥
## ការពិនិត្យតាមដាននិងការវាយតម្លៃ

### ប្រការ ៤៤.- ការវាយតម្លៃផ្ទៃក្នុង

ផ្នែកធានាគុណភាពអប់រំផ្ទៃក្នុងរបស់គ្រឹះស្ថានឧត្តមសិក្សា ត្រូវធ្វើការស្វ័យវាយតម្លៃលើការអនុវត្ត ការបង្រៀន ការសិក្សា ការស្រាវជ្រាវ និងការអនុវត្តផ្សេងៗទៀត ស្របតាមផែនការបណ្តុះ-មណ្ឌាលរបស់គ្រឹះស្ថាន។

### ប្រការ ៤៥.- ការពិនិត្យតាមដាន

ក្រសួងអប់រំ យុវជន និងកីឡា មានយន្តការនៃការចុះពិនិត្យតាមដាន និងធ្វើការវាយតម្លៃលើការអនុវត្តរបស់គ្រឹះស្ថានឧត្តមសិក្សា ស្របតាមលក្ខខណ្ឌនិងលក្ខណវិនិច្ឆ័យលម្អិតដែលមានចែងក្នុងប្រកាសនេះ ដើម្បីធានាលើកកម្ពស់គុណភាព និងប្រសិទ្ធិភាពនៃការអប់រំនៅក្នុងគ្រឹះស្ថានឧត្តមសិក្សា។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

### ប្រការ ៤៦.- និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

### ប្រការ ៤៧.- អនុភាពអនុវត្ត

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ ប្រធាននាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ ប្រធាននាយកដ្ឋានឧត្តមសិក្សា សាកលវិទ្យាធិការ/នាយកគ្រឹះស្ថានឧត្តមសិក្សា និងអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ២០១២

អ៊ឹម_សិទ្ធី

**កន្លែងទទួល:**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -គ្រប់ក្រសួងអាណាព្យាបាលគ្រឹះស្ថានឧត្តមសិក្សា
- -រាជបណ្ឌិត្យសភាកម្ពុជា
- -អង្គភាពក្រោមឱវាទក្រសួង
  "ដើម្បីជូនជ្រាប"
- -ដូចប្រការ៤៧ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្ត នា. នីតិកម្ម

## សន្ទានុក្រម

**១.ការគ្រប់គ្រងព័ត៌មានសិក្សា** សំដៅដល់ការគ្រប់គ្រងបញ្ជីឈ្មោះនិស្សិតប្រចាំឆ្នាំសិក្សាទៅតាមកម្រិតសិក្សា ប្រធានបទស្រាវជ្រាវរបស់បេក្ខជនបណ្ឌិតម្នាក់ៗ និងក្រុមសាស្ត្រាចារ្យណែនាំ កម្រិតជឿនលឿននៃការស្រាវជ្រាវនិក្ខេបបទរបស់បេក្ខជនបណ្ឌិតម្នាក់ៗ ព័ត៌មានទូទៅអំពីការអនុវត្តកម្មវិធីសិក្សាដែលពាក់ព័ន្ធនឹងមុខវិជ្ជាសិក្សានីមួយៗ និងការងារស្រាវជ្រាវព្រមទាំងកិច្ចការងារដែលត្រូវនិងបានបំពេញដោយបេក្ខជនបណ្ឌិតក្នុងដំណើរការសិក្សានិងព័ត៌មានគ្រប់ៗ អំពីការរៀបចំចាត់ចែងនិងគ្រប់គ្រងរបស់កម្មវិធីសិក្សាថ្នាក់បណ្ឌិត។

**២.ព័ត៌មានដែលត្រូវផ្សព្វផ្សាយ** សំដៅដល់ព័ត៌មានដែលពិពណ៌នាអំពីទីតាំងនិងមូលដ្ឋានសម្ភារសម្រាប់ទ្រទ្រង់ដំណើរការបណ្តុះបណ្តាល អាសយដ្ឋានទំនាក់ទំនង កម្មវិធីសិក្សា ជំនាញដែលជ្រើសរើស និងចំនួននិស្សិតដែលគ្រោងជ្រើសរើស លក្ខខណ្ឌសម្រាប់ការជ្រើសរើស ចំនួនសាស្ត្រាចារ្យបង្រៀន សាស្ត្រាចារ្យណែនាំ និងរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់បណ្ឌិត លិខិតបទដ្ឋានដែលអនុញ្ញាតឱ្យបើកដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិត ថ្លៃសិក្សា រចនាសម្ព័ន្ធថ្លៃសិក្សា រយៈពេលសិក្សា (អប្បបរមានិងអតិបរមា) និងព័ត៌មានចាំបាច់ផ្សេងៗទៀត។

**៣.ការរៀបចំផែនការសកម្មភាពរបស់និស្សិត** សំដៅដល់ការរៀបចំអត្ថបទស្រាវជ្រាវនិងការត្រួតពិនិត្យឡើងវិញប្រចាំឆ្នាំ របាយការណ៍អំពីភាពជឿនលឿននៅតាមឆមាសនីមួយៗ ផ្តល់បទបង្ហាញជាផ្លូវការតាមរយៈសិក្ខាសាលាប្រចាំឆ្នាំ រៀបចំការចុះផ្សាយអត្ថបទស្រាវជ្រាវយ៉ាងតិចឱ្យបានតាមចំនួនកំណត់មុនពេលឡើងការពារបញ្ចប់ រៀបចំនិងដាក់ជូននិក្ខេបបទចុងក្រោយសម្រាប់ការពិនិត្យនិងវាយតម្លៃនិងការការពារបញ្ចប់។

**៤.ប្រភេទកម្មវិធីសិក្សាពេញម៉ោង** សំដៅដល់កម្មវិធីសិក្សាសម្រាប់និស្សិតដែលបានត្រៀមខ្លួនជាស្រេចប្រើប្រាស់ពេលវេលាពេញលេញក្នុងមួយសប្តាហ៍ ដើម្បីការសិក្សាស្រាវជ្រាវរបស់ខ្លួន។

**៥.ប្រភេទកម្មវិធីសិក្សាមិនពេញម៉ោង** សំដៅដល់កម្មវិធីសិក្សាសម្រាប់និស្សិតដែលមិនមានពេលវេលាពេញលេញក្នុងមួយសប្តាហ៍ ដើម្បីការសិក្សាស្រាវជ្រាវរបស់ខ្លួន។

**៦.គ្រឹះស្ថានឧត្តមសិក្សា** សំដៅដល់មជ្ឈមណ្ឌលអប់រំសិក្សាដែលផ្តល់ការអប់រំបណ្តុះបណ្តាលជំនាញឯកទេសកម្រិតក្រោយមធ្យមសិក្សា។

**៧. រចនាសម្ព័ន្ធគ្រប់គ្រងពិតប្រាកដ** សំដៅដល់រចនាសម្ព័ន្ធគ្រប់គ្រងមួយដែលមានមន្ត្រីបំពេញការងារតាមផ្នែកនីមួយៗពេញម៉ោងនិងពិតប្រាកដ។

**៨. គុណវុឌ្ឍិសាស្ត្រាចារ្យបង្រៀន** សំដៅដល់លក្ខណៈសម្បត្តិរបស់សាស្ត្រាចារ្យដូចជា(១)ចរិយាសម្បត្តិនិងសីលធម៌ (២)សញ្ញាបត្របណ្ឌិត ឬគោរម្យងារជាសាស្ត្រាចារ្យលើមុខជំនាញឬវិស័យសមស្របទៅនឹងមុខវិជ្ជាដែលនឹងត្រូវទទួលបន្ទុកបង្រៀននៅក្នុងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិត និង(៣) សមត្ថភាពជំនាញឯកទេសលើមុខវិជ្ជាសិក្សាដទៃទៀតហើយបច្ចុប្បន្នកំពុងធ្វើសកម្មភាព

ស្រាវជ្រាវនិងធ្លាប់បោះពុម្ពផ្សាយអត្ថបទវិទ្យាសាស្ត្រនិងសៀវភៅសិក្សានិងធ្លាប់បានបង្រៀនកម្មវិធីថ្នាក់បណ្ឌិតនេះមួយរយៈកាលកន្លងមក។

**៩.គុណវុឌ្ឍិសាស្ត្រាចារ្យណែនាំគោល** សំដៅដល់លក្ខណៈសម្បត្តិរបស់សាស្ត្រាចារ្យដូចជា (១) គោរម្យងារជាសាស្ត្រាចារ្យឬសាស្ត្រាចារ្យរង ដែលមានសញ្ញាបត្របណ្ឌិត។ បើពុំទាន់មានគោរម្យងារវិទ្យាសាស្ត្រនេះទេ ត្រូវមានអតីតភាពសញ្ញាបត្របណ្ឌិតយ៉ាងតិចត្រឹម៣ឆ្នាំ (២)បានឆ្លងកាត់វគ្គបំប៉នគុណវុឌ្ឍិជាសាស្ត្រាចារ្យណែនាំគោលតាមស្តង់ដារដែលបានរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា ឬស្ថាប័នប្រហាក់ប្រហែល ដើម្បីជាការទទួលស្គាល់អំពីគុណវុឌ្ឍិនៃការណែនាំនិក្ខេបបទ (៣)ស្នាដៃនិងកិត្តិនាមក្នុងការចុះផ្សាយអត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រជាតិនិងអន្តរជាតិ (៤)មានស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការណែនាំវិទ្យាសាស្ត្រ (៥)អាចប្រើភាសាអង់គ្លេសឬភាសាអន្តរជាតិណាមួយបានល្អក្នុងការស្រាវជ្រាវនិងផ្លាស់ប្តូរវិទ្យាសាស្ត្រជាអន្តរជាតិ និង (៦)មានគុណធម៌និងសីលធម៌ជាអ្នកអប់រំគំរូ។

**១០.ភារកិច្ចសាស្ត្រាចារ្យណែនាំគោល** សំដៅដល់ការទទួលខុសត្រូវដូចជា ការរៀបចំជំនួបជាទៀងទាត់និងសិក្ខាសាលាជាមួយបេក្ខជនបណ្ឌិត ការណែនាំពីបទដ្ឋាន(ស្តង់ដា)បច្ចេកទេស និងវិធីសាស្ត្រដែលបានតម្រូវ ការគ្រោងរៀបចំនិងយល់ព្រមចំពោះបញ្ជីអំពីចំណុចគោលដៅនិងបញ្ហាសំខាន់ៗមួយចំនួនជាមួយបេក្ខជនបណ្ឌិត ហើយប្រើដើម្បីត្រួតពិនិត្យដំណើររីកចម្រើនរបស់បេក្ខជន ការទារកិច្ចការសំណេរពីបេក្ខជនតាមកាលកំណត់និងផ្តល់មតិយោបល់រិះគន់ស្ថាបនាត្រឡប់វិញតាមពេលវេលាសមស្រប។ ការចាត់ចែងឱ្យបេក្ខជនអនុវត្តការធ្វើបទបង្ហាញផ្ទាល់មាត់អំពីការងារស្រាវជ្រាវរបស់គេនៅក្នុងសិក្ខាសាលា និងសន្និសីទ ការធានាថាបេក្ខជនត្រូវប្រុងប្រយ័ត្នអំពីកង្វះខាតនៃភាពជឿនលឿន ឬការបរាជ័យក្នុងការឈានទៅដល់កម្រិតស្តង់ដារកិច្ចការដែលអាចទទួលយកបាន ការចាត់ចែងរកសាស្ត្រាចារ្យណែនាំជំនួសក្នុងករណីដែលគាត់ពុំមានលទ្ធភាពសម្រាប់រយៈពេលណាមួយ ការរៀបចំរបាយការណ៍ផ្សេងៗដែលតម្រូវដោយក្រុមប្រឹក្សាវិទ្យាសាស្ត្រ ការជំរុញឱ្យបេក្ខជនបណ្ឌិតអាចចុះផ្សាយអត្ថបទក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រ ចូលរួមសន្និសីទផ្សព្វផ្សាយអត្ថបទ ចូលរួមសមាគមវិជ្ជាជីវៈ។ល។ ការជួយបេក្ខជនក្នុងការរៀបចំឯកសារនិងប្រគល់និក្ខេបបទចុងក្រោយនិងក្នុងការត្រៀមខ្លួនសម្រាប់ការការពារនិក្ខេបបទដោយផ្ទាល់មាត់ ការប្រកាសថានិក្ខេបបទត្រូវបានរួចរាល់សម្រាប់ការការពារបញ្ចប់ និងការទទួលខុសត្រូវលើគុណភាពនិក្ខេបបទរបស់និស្សិត។

**១១.គណៈកម្មការសាស្ត្រាចារ្យណែនាំ** សំដៅដល់ក្រុមសាស្ត្រាចារ្យ ដែលមានសមាជិកបី(៣)រូប គឺប្រធានមួយរូបជាសាស្ត្រាចារ្យណែនាំគោល និងសាស្ត្រាចារ្យណែនាំរង ឬសហសាស្ត្រាចារ្យណែនាំចំនួនពីរ(២)រូបទៀតជាសមាជិក ដែលជាសាស្ត្រាចារ្យនៅក្នុងឬក្រៅស្ថាប័នបណ្តុះបណ្តាលក្នុងឬក្រៅប្រទេស។

**១២.ការសិក្សាមុខវិជ្ជាបំពេញបន្ថែម** សំដៅដល់ការសិក្សាមុខវិជ្ជាទាំងឡាយនៅក្នុងកម្មវិធីបរិញ្ញាបត្រឬបរិញ្ញាបត្រជាន់ខ្ពស់ ដែលនិស្សិតមិនបានឆ្លងកាត់។ មុខវិជ្ជាសិក្សាទាំងនេះសំដៅឱ្យនិស្សិតមានចំណេះដឹងមូលដ្ឋានរឹងមាំ និងកម្រិតមុខជំនាញគ្រប់គ្រាន់សម្រាប់អនុវត្តបាននូវភារកិច្ចស្រាវជ្រាវជានិស្សិតថ្នាក់បណ្ឌិត។ ចំពោះនិស្សិតដែលមានបរិញ្ញាបត្រជាន់ខ្ពស់ដែរ ប៉ុន្តែជានិស្សិតមិនធ្វើនិក្ខេបបទ មុខវិជ្ជាបំពេញបន្ថែមអាចជាបណ្ដាមុខវិជ្ជាពាក់ព័ន្ធនានា និងវិធីសាស្ត្រស្រាវជ្រាវដែលពុំទាន់បានសិក្សាស៊ីជម្រៅនៅកម្រិតបរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់។ ចំពោះនិស្សិតដែលមានបរិញ្ញាបត្រជាន់ខ្ពស់ ដោយសរសេរនិក្ខេបបទ ហើយមានជំនាញប្រហាក់ប្រហែលឬមិនដូចគ្នាទៅនឹងជំនាញសិក្សាថ្នាក់បណ្ឌិត ប្រធានក្រុមមុខជំនាញនិងព្រឹទ្ធបុរសមហាវិទ្យាល័យសហការគ្នា ដោយប្រៀបធៀបមុខវិជ្ជារបស់ពួកគេដែលបានរៀននៅបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ដើម្បីកំណត់អំពីមុខវិជ្ជាបំពេញបន្ថែមដែលត្រូវឱ្យសិក្សា។

**១៣.ការសិក្សាមុខវិជ្ជាកម្រិតបណ្ឌិត** សំដៅដល់ការសិក្សាមុខវិជ្ជារួម និងមុខវិជ្ជាមុខជំនាញ ដែលត្រូវបានអនុវត្តនៅក្នុងឆ្នាំសិក្សាទី១ និងអាចបន្តទៅឆ្នាំសិក្សាទី២ ហើយដែលគ្រឹះស្ថានបណ្ដុះបណ្ដាលកម្មវិធីថ្នាក់បណ្ឌិតបានរៀបចំរួចជាស្រេច។

**១៤.ការសិក្សាមុខវិជ្ជាតម្រង់ទិសបណ្ឌិត** សំដៅដល់ការសិក្សាទៅលើមុខវិជ្ជាចំនួន៣(បី)ដែលពាក់ព័ន្ធទៅនឹងប្រធានបទស្រាវជ្រាវរបស់និស្សិត ហើយដែលកំណត់ដោយគណៈកម្មការសាស្ត្រាចារ្យណែនាំ និងមានការឯកភាពពីក្រុមប្រឹក្សាវិទ្យាសាស្ត្រ។

**១៥.ការរៀបចំសារណាបទពិសោធវិជ្ជាជីវៈ** សំដៅដល់របាយការណ៍វិទ្យាសាស្ត្រមួយដែលបានមកពីការប្រតិបត្តិរបស់និស្សិតនៅស្ថាប័នណាមួយក្នុងរយៈពេលមួយជាកំណត់។ របាយការណ៍នេះមានទម្រង់ជារបាយការណ៍ស្រាវជ្រាវផង និងជាបទពិសោធដកស្រង់ពីការប្រតិបត្តិវិជ្ជាជីវៈផង។

**១៦. ការប្តូរប្រធានបទ** អាចអនុវត្តទៅបានតែក្នុងរយៈពេលមួយភាគបី(១/៣)នៃរយៈពេលបណ្ដុះបណ្ដាលសរុប។

**១៧.ការបន្ថែមឬប្តូរសាស្ត្រាចារ្យណែនាំ** អាចអនុវត្តបានតែក្នុងរយៈពេលមួយឆ្នាំយ៉ាងតិច មុនពេលដែលនិស្សិតឡើងការពារនិក្ខេបបទបញ្ចប់។

**១៨.ការព្យួរការសិក្សា** អាចអនុញ្ញាតឱ្យបានតែមួយដងគត់ហើយមិនលើសពីមួយឆ្នាំក្នុងរយៈពេលសិក្សា។ និស្សិតត្រូវដាក់ពាក្យសុំព្យួរការសិក្សាបណ្ដោះអាសន្ន ដោយរក្សាទុកលទ្ធផលសិក្សាបានលុះត្រាតែមានមូលហេតុត្រឹមត្រូវ។

**១៩.ការផ្ទេរការសិក្សា** សំដៅដល់ការប្តូរគ្រឹះស្ថានសិក្សា។ និស្សិតត្រូវបានអនុញ្ញាតឱ្យផ្ទេរការសិក្សាពីគ្រឹះស្ថានមួយទៅគ្រឹះស្ថានមួយទៀតបាន លុះត្រាតែលទ្ធផលនៃការសិក្សារបស់ខ្លួនបានបញ្ចប់យ៉ាងច្រើនត្រឹមមួយភាគបី(១/៣)នៃលទ្ធផលសិក្សាសរុប។ ប៉ុន្តែមិនអនុញ្ញាតឱ្យផ្ទេរការសិក្សា ក្នុងករណីដែលកំពុងសិក្សានៅក្នុងឆមាស និងនៅក្នុងដំណាក់កាលកំពុងទទួលពិន័យចាប់ពីការព្រមានឡើងទៅ។

**២០.និក្ខេបបទបណ្ឌិត** សំដៅដល់ប្រធានបទនិក្ខេបបទស្រាវជ្រាវរបស់បេក្ខជនបណ្ឌិតម្នាក់ៗ ហើយត្រូវតែជាស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្រដើមដំបូងគេកម្រិតខ្ពស់ ថ្មៃប្រឌិតក្នុងវិស័យស្រាវជ្រាវដែលមានការរួមចំណែកអំពីទ្រឹស្តី ដែលជាចំណេះដឹងឬដំណោះស្រាយថ្មីមានតម្លៃសម្រាប់ការអភិវឌ្ឍលើកកម្ពស់ចំណេះដឹងវិទ្យាសាស្ត្រក្នុងវិស័យស្រាវជ្រាវ ឬវិធីដោះស្រាយប្រកបដោយភាពច្នៃប្រឌិតនូវរាល់បញ្ហាដែលបានចោទឡើងចំពោះមុខជំនាញវិទ្យាសាស្ត្រ ឬ ការអនុវត្តជាក់ស្តែងក្នុងសង្គម។

**២១. ការវាយតម្លៃនិក្ខេបបទសាកល្បង** សំដៅដល់ការបញ្ចេញយោបល់វាយតម្លៃ របស់សមាជិកគណៈកម្មការវាយតម្លៃគ្រប់រូបទៅលើទ្រង់ទ្រាយនិងខ្លឹមសារនិក្ខេបបទដូចជារំលឹកទ្រឹស្តីនិងការសំយោគឯកសារពាក់ព័ន្ធ ការបកស្រាយលទ្ធផលនិងការវិភាគទិន្នន័យ និងសំណូមពរឱ្យបេក្ខជនធ្វើការកែលម្អនិងបំពេញបន្ថែមចំណុចខ្វះខាត។ និក្ខេបបទដែលបានការពារសាកល្បងរួចហើយអាចអនុញ្ញាតឱ្យបន្តសុំការការពារបញ្ចប់ដែលមិនបាច់មានការកែលម្អ ឬកែលម្អតិចតួចដោយមានការយល់ព្រមពីសមាជិកគណៈកម្មការការពារសាកល្បងគាំទ្រចាប់ពីប្រាំ(៥)នាក់ឡើងទៅ។ បើសមាជិកគណៈកម្មការណាម្នាក់អវត្តមាន ត្រូវធ្វើលិខិតវាយតម្លៃបញ្ជូនមកឱ្យបានមុនពេលការការពារសាកល្បង។

**២២.ការវាយតម្លៃនិក្ខេបបទដោយគណៈកម្មការពិនិត្យនិងវាយតម្លៃឯករាជ្យ** សំដៅដល់របាយការណ៍នៃការវាយតម្លៃលើសេចក្តីផ្តើម ប្រវត្តិពាក់ព័ន្ធនឹងប្រធានបទស្រាវជ្រាវ គោលបំណងនិងវត្ថុបំណងស្រាវជ្រាវ មូលដ្ឋានទ្រឹស្តីនិងបញ្ញត្តិវិទ្យាសាស្ត្រ វិធីសាស្ត្រស្រាវជ្រាវ លទ្ធផលស្រាវជ្រាវនិងការបកស្រាយពិភាក្សា ការសន្និដ្ឋាន និងអនុសាសន៍សម្រាប់ការស្រាវជ្រាវបន្ត ទម្រង់នៃការសរសេរឯកសារយោងនិងគន្ថនិទ្ទេស និងចំណុចបំពេញបន្ថែមថ្មីរបស់និក្ខេបបទ។ ការបញ្ជាក់ទៅលើខ្លឹមសារដែលបានលើកយកមកបកស្រាយក្នុងជំពូកនីមួយៗ គឺគ្មានការឃ្លាតឆ្ងាយពីប្រធានបទ។ ស្នាដៃដែលបានចុះផ្សាយនៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រជាតិនិងអន្តរជាតិ មិនត្រូវឃ្លាតឆ្ងាយពីប្រធានបទស្រាវជ្រាវដែលបេក្ខជនបានស្នើសុំ។ ផ្នែកខាងដើមនៃរបាយការណ៍វាយតម្លៃ ត្រូវលើកឡើងឱ្យបានគ្រប់គ្រាន់នូវព័ត៌មានដូចជា ឈ្មោះប្រធានបទ មុខជំនាញ ឈ្មោះបេក្ខជន ភារកិច្ចនិងតួនាទីរបស់សាស្ត្រាចារ្យវាយតម្លៃ មុខជំនាញនិងអង្គភាពបម្រើការ។ នៅផ្នែកចុងក្រោយនៃរបាយការណ៍របស់ខ្លួន ត្រូវបញ្ជាក់ពីយោបល់សរុបចុងក្រោយទៅលើគុណភាពនិក្ខេបបទ។

**២៣.លក្ខខណ្ឌសម្រាប់បញ្ចប់ការសិក្សាថ្នាក់បណ្ឌិត** សំដៅដល់ការសន្សំក្រេឌីតសិក្សារបស់និស្សិតឱ្យបានគ្រប់ចំនួនកំណត់ (អប្បបរមា៥៤ក្រេឌីត) ដែលបានបញ្ចប់ដោយជោគជ័យពីគ្រប់ផ្នែកសិក្សានីមួយៗ។

**២៤.ការវាយតម្លៃនិក្ខេបបទបញ្ចប់** សំដៅដល់ការប្រកាសនូវលទ្ធផលតាមកម្រិតដូចជា (១) និក្ខេបបទមានតម្លៃស័ក្តិសមជានិក្ខេបបទកម្រិតបណ្ឌិត ឬ (២)និក្ខេបបទមានតម្លៃស័ក្តិសមជានិក្ខេបបទកម្រិតបណ្ឌិតបន្ទាប់ពីបានកែលម្អបន្តិចបន្តួចតាមការស្នើសុំ ឬ (៣)និក្ខេបបទមានតម្លៃជានិក្ខេបបទកម្រិតបណ្ឌិត បន្ទាប់ពីមានការកែលម្អឡើងវិញតាមការណែនាំរបស់គណៈកម្មការវាយ

តម្លៃ។ ក្នុងករណីនេះនិស្សិតត្រូវពិគ្រោះយោបល់ជាមួយសាស្ត្រាចារ្យណែនាំគោល ដើម្បីកែលម្អនិក្ខេបបទឡើងវិញនិងដាក់ជូនគណៈកម្មការវាយតម្លៃនិក្ខេបបទបញ្ចប់ពិនិត្យឯកភាព មុនដាក់ជូនគ្រឹះស្ថានឧត្តមសិក្សា ឬ(៤)និក្ខេបបទមិនទាន់មានតម្លៃជានិក្ខេបបទកម្រិតបណ្ឌិតនៅឡើយ។ ក្នុងករណីនេះ បេក្ខជនអាចស្នើសុំដាក់និក្ខេបបទពិនិត្យនិងវាយតម្លៃឡើងវិញក្នុងរយៈពេលណាមួយដែលកំណត់ដោយគណៈកម្មការវាយតម្លៃនិក្ខេបបទបញ្ចប់ (យ៉ាងតិចមួយឆ្នាំ) ប៉ុន្តែមិនអនុញ្ញាតឱ្យការពារជាលើកទីបី ឬ (៥)សញ្ញាបត្របណ្ឌិតមិនត្រូវបានប្រគល់ជូន ហើយការចុះឈ្មោះជានិស្សិតថ្នាក់បណ្ឌិតត្រូវបញ្ឈប់។

**២៥.គុណភាពនិក្ខេបបទ** សំដៅដល់និក្ខេបបទដែលត្រូវតែអនុវត្តដោយបេក្ខជនបណ្ឌិតផ្ទាល់ និងបំពេញតាមតម្រូវការនៃគោលបំណង និងលក្ខខណ្ឌដែលបានកំណត់។ ខ្លឹមសារនិក្ខេបបទបណ្ឌិតត្រូវមានបរិមាណពី១០០ទៅ៣០០ទំព័រA4 ដែលនៅក្នុងនោះយ៉ាងតិច ៥០%(ហាសិបភាគរយ) គឺជាការបង្ហាញអំពីលទ្ធផលស្រាវជ្រាវ ការវិភាគ សំយោគឯកសារពាក់ព័ន្ធ និងការបកស្រាយផ្ទាល់របស់បេក្ខជន។

**២៦. សំណុំឯកសារសម្រាប់សុំការពារនិក្ខេបបទបញ្ចប់** សំដៅដល់លិខិតស្នើសុំការការពារនិក្ខេបបទរបស់បេក្ខជនបណ្ឌិត លិខិតស្នើសុំឱ្យបេក្ខជនការពាររបស់សាស្ត្រាចារ្យណែនាំគោលដែលមានអំណះអំណាងទៅលើស្នាដៃស្រាវជ្រាវនិងគុណភាពនិក្ខេបបទរបស់បេក្ខជន។ ស្នាដៃអត្ថបទចុះផ្សាយលើទស្សនាវដ្ដីវិទ្យាសាស្ត្ររបស់បេក្ខជនកម្រិតជាតិចំនួនពីរ ឬកម្រិតអន្តរជាតិចំនួនមួយ (ថតចម្លង) លិខិតវាយតម្លៃលើទ្រង់ទ្រាយនិងគុណភាពនិក្ខេបបទរបស់គណៈកម្មការពិនិត្យនិងវាយតម្លៃឯករាជ្យទាំងបី(៣)រូប ដោយបិទស្រោមជិត លិខិតស្នើសុំអនុញ្ញាតឱ្យបេក្ខជនការពារបញ្ចប់របស់គ្រឹះស្ថានឧត្តមសិក្សាដែលមានអំណះអំណាងទៅលើទ្រង់ទ្រាយខ្លឹមសារនិងលក្ខណៈ
វិទ្យាសាស្ត្រនៃនិក្ខេបបទរបស់បេក្ខជន ពង្រាងលិខិតឧទ្ទេសនាមសុំបង្កើតគណៈកម្មការវាយតម្លៃនិក្ខេបបទដែលស្នើឡើងដោយគ្រឹះស្ថានឧត្តមសិក្សា ប្រវត្តិរូបសង្ខេបរបស់បេក្ខជនបណ្ឌិត និងព្រឹត្តិបត្រពិន្ទុគ្រប់មុខវិជ្ជាសិក្សាតាមកម្មវិធីកំណត់របស់គ្រឹះស្ថានឧត្តមសិក្សា ច្បាប់ថតចម្លងសញ្ញាបត្របរិញ្ញាបត្រនិងបរិញ្ញាបត្រជាន់ខ្ពស់ដោយមានការបញ្ជាក់ពីសាលារាជធានី ឬសាលាខេត្ត ឬសាលាក្រុង ស្រុក ខណ្ឌ។

**២៧.សំណុំឯកសារសម្រាប់ការផ្ដល់សញ្ញាបត្រ** សំដៅដល់កំណត់ហេតុលម្អិតពេលការពារនិក្ខេបបទបញ្ចប់ សេចក្ដីសម្រេចរបស់គណៈកម្មការវាយតម្លៃនិក្ខេបបទ លិខិតវាយតម្លៃរបស់គណៈកម្មការគ្រប់រូប លិខិតឧទ្ទេសនាមបង្កើតគណៈកម្មការពិនិត្យនិងវាយតម្លៃឯករាជ្យ លិខិតឧទ្ទេសនាមបង្កើតគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទបញ្ចប់ លិខិតកែលម្អនិក្ខេបបទរបស់បេក្ខជនដែលមានការឯកភាពពីសាស្ត្រាចារ្យណែនាំគោលនិងប្រធានគណៈកម្មការវាយតម្លៃ និងប្រវត្តិរូប ដោយភ្ជាប់ជាមួយនូវរូបថតទើបថតថ្មីទំហំ 4x6 ចំនួន៤សន្លឹករបស់បេក្ខជន។